# ក្រុមពិគ្រោះយោបល់កម្មវិធីរេដ+

## ១. វត្ថុបំណង

ក្រុមពិគ្រោះយោបល់រេដ+ ផ្តល់យោបល់ឲ្យក្រុមការងាររេដ+ លើដំណើរការត្រៀមខ្លួនរួចជាស្រេចរបស់រេដ+ និងផ្តល់វេទិការដើម្បីតំណាងឲ្យទស្សនៈរបស់ភាគីពាក់ព័ន្ធក្នុងមូលដ្ឋានជាពិសេស ពីសំណាក់សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។

## ២. វិសាលភាពការងារ

ក្រុមពិគ្រោះយោបល់ ទទួលខុសត្រូវផ្តល់ជាបណ្តាញតភ្ជាប់រវាងកម្មវិធីរេដ+កម្ពុជា ជាមួយបណ្តាញ ក្រុមភាគីពាក់ព័ន្ធដែលមាន។

## ៣. ការទទួលខុសត្រូវ

សមាជិកក្រុមពិគ្រោះយោបល់រេដ+ទទួលខុសត្រូវក្នុងការៈ

- ផ្តល់យោបល់ដល់ក្រុមការងាររេដ+
- ប្រមូល សង្ខេប និងរៀបចំយោបល់ សរសេរព្រាងរបាយការណ៍ និងសំណើសេចក្តីសម្រេចចិត្តរបស់ក្រុមការងាររេដ+ ដែលបានមកពីអ្នកដែលខ្លួនតំណាងឲ្យរៀងៗខ្លួន។ ក្រុមការងារ ចាំបាច់ត្រូវបញ្ជូនឯកសារទាំងនេះ ទៅឲ្យក្រុមពិគ្រោះយោបល់ និងត្រូវឆ្លើយតបចំពោះយោបល់ ទាំងឡាយដែលត្រូវបានលើកឡើងឲ្យទាន់ពេលវេលា។ អ្នកតំណាងចាំបាច់ត្រូវចែករំលែកព័ត៌មានទាំងអស់នេះ ជាមួយអ្នកដែលខ្លួនតំណាងឲ្យ។
- ចូលរួមក្នុងការព្រាងរបាយការណ៍ និងការទាក់ទងផ្សេងៗជាក្រុមការងាររេដ+។
- ជួបប្រជុំជារៀងរាល់ខែ ឬរៀងរាល់ពីរខែម្តង ទៅតាមតម្រូវការ ជាមួយអ្នកតំណាងក្រុមការងាររេដ+ (លេខាធិការដ្ឋានក្រុមការងាររេដ+) ដើម្បីពិភាក្សាដំណើរការត្រៀមខ្លួនរួចជាស្រេចរបស់រេដ+ ឬប្រជុំញឹកញាប់ជាងនេះតាមការចាំបាច់។ រាល់កិច្ចប្រជុំនឹងត្រូវមានកំណត់ហេតុ។
- ចែករំលែកព័ត៌មាន ស្តីពី ការអភិវឌ្ឍទាក់ទងនឹងរេដ+ ទៅដល់អ្នកដែលខ្លួនតំណាងឲ្យក្រុមការងាររេដ+ លេខាធិការដ្ឋានក្រុមការងាររេដ+ និងសមាជិកដទៃទៀតរបស់ក្រុមពិគ្រោះយោបល់។
- ផ្តល់យោបល់ ឬសំណើជាលាយលក្ខណ៍អក្សរដល់ក្រុមកការងាររេដ+ ស្តីពីបញ្ហា

កង្វល់នានា តាងនាមឲ្យអ្នកដែលខ្លួនតំណាងឲ្យ។

- ផ្តល់យោបល់ជាក់លាក់លើបញ្ហាសំខាន់ៗ ដូចជា ការពិគ្រោះយោបល់ និងការចូលរួម ឬ ការរក្សា សន្តិសុខសង្គម និងបរិស្ថានជាដើម។
- សម្របសម្រួល និងផ្តល់ព័ត៌មានដល់អ្នកដែលខ្លួនតំណាងឲ្យរៀងៗខ្លួន។ ការងារនេះ ប្រហែលជាតម្រូវឲ្យមានកិច្ចប្រជុំជាប្រចាំជាមួយក្រុមនីមួយៗ។
- ផ្តល់អ្នកតំណាងសម្រាប់ក្រុមការងារបច្ចេកទេសពិគ្រោះយោបល់ និងក្រុមបច្ចេកទេស សុវត្ថិភាព ដែលនឹងគាំទ្រដល់ការពិគ្រោះយោបល់ និងសកម្មភាពលើកកម្ពស់ការ យល់ដឹងក្រោមដំណើការត្រៀមខ្លួនរួចជាស្រេចរបស់កម្មវិធីរេដ+ថ្នាក់ជាតិ។

## ៤. សមាជិកភាព

### ក. សមាសភាព

**ក្រុមពិគ្រោះយោបល់ ត្រូវមានសមាជិក ១៨រូប រួមមានៈ**

- សមាជិក ២រូប មកពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និង ២រូប មកពីអង្គការមិនមែន រដ្ឋាភិបាលជាតិ។ សមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាល គួរត្រូវបានជ្រើសរើស ដោយប្រើយន្តការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាល ដែលមានរួមទាំងក្រុម ការងារក្រៅផ្លូវការរេដ+ បណ្តាញនៃការផ្លាស់ប្តូរអាកាសធាតុ និងបណ្តាញព្រៃឈើ ជីវភាពរស់នៅ និងដំណាំចំការ។
- សមាជិក ២រូប មកពីសង្គមស៊ីវិល និង ២រូប មកពីក្រុមជនជាតិដើមភាគតិច។ សមាជិក ទាំងនេះ នឹងត្រូវជ្រើសរើសដោយសង្គមស៊ីវិល និងបណ្តាញជនជាតិដើមភាគតិច ដែលមាន ហើយត្រូវមកពីអង្គការមិនមែនដ្ឋាភិបាល អង្គការសហគមន៍ និងក្រុម សហគមន៍នៅថ្នាក់ជាតិ/ក្រោមជាតិ។
- សមាជិក ២រូប មកពីវិស័យឯកជន ទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ ឬការអភិវឌ្ឍ គម្រោងរេដ+។
- សមាជិក ២រូប មកពីស្ថាប័នសិក្សាធិការ។
- សមាជិក ៦រូប តំណាងឲ្យបណ្តាញសហគមន៍ព្រៃឈើ (២រូប) សហគមន៍ជលផល (២រូប) និងសហគមន៍តំបន់ការពារ (២រូប) ហើយអ្នកតំណាង គឺជាសមាជិករបស់ ក្រុមបណ្តាញទាំងបីនេះ។

### ខ. តំណាងបម្រុង

រាល់សមាជិកក្រុមការងារពិគ្រោះយោបល់ត្រូវមានតំណាងបម្រុង។ ហើយតំណាងបម្រុងនេះ ត្រូវតែបំពេញនូវល័ក្ខខ័ណ្ឌតម្រូវការទាំងអស់ដែរ។ តំណាងបម្រុងក៏ត្រូវតែទទួលស្គាល់ដោយក្រុមពិគ្រោះយោបល់ និងធ្វើការជូនដំណឹងទៅក្រុមការងារលេខាធិការរេដ+។

### គ. រយៈពេលបំពេញការងារ

សមាជិកក្រុមពិគ្រោះយោបល់ នឹងមានសុពលភាពការងាររយៈពេល ៣ឆ្នាំ ហើយដំណើការបន្តដោយដំណើការពិនិត្យឡើងវិញ ដែលអាចជាការចាត់តាំងបន្ត។ សមាជិកក្រុមពិគ្រោះយោបល់ថ្មី នឹងត្រូវជ្រើសរើសដោយគោរពទៅតាមល័ក្ខខ័ណ្ឌជ្រើសរើស ដោយផ្អែកទៅតាមតំណាងរបស់ក្រុមការងារនីមួយៗ។

ក្នុងករណី សមាជិកក្រុមពិគ្រោះយោបល់ណាមួយមិនគោរពទៅតាមតម្រូវការ/ការទទួលខុសត្រូវ ក្នុងនាមជាតំណាងក្រុម ដំណើការពិនិត្យឡើងវិញពីសមត្ថភាពរបស់តំណាងនោះ នឹងត្រូវធ្វើឡើងវិញដោយក្រុមនីមួយៗ។

### ឃ. ដំណើការជ្រើសរើស

ដំណើការជ្រើសរើសតំណាងជាសមាជិកក្រុមពិគ្រោះយោបល់ នឹងត្រូវធ្វើឡើងដោយមានការបោះឆ្នោតរួមគ្នានៅក្នុងសិក្ខាសាលារួមមួយនៅថ្ងៃទី០៤-០៥ ខែកក្កដា ឆ្នាំ២០១៣។

## ៥. ប្រតិបត្តិការ

អ្នកតំណាងលេខាធិការដ្ឋានក្រុមការងាររេដ+ ធ្វើជាសហប្រធានរបស់ក្រុមពិគ្រោះយោបល់ ព្រមជាមួយសមាជិកមួយរូបរបស់ក្រុមពិគ្រោះយោបល់ លើមូលដ្ឋានវង្វិលជុំ។

ក្រុមពិគ្រោះយោបល់នឹងជួបប្រជុំយ៉ាងហោចណាស់មួយដងរៀងរាល់ត្រីមាស ជាមួយអ្នកតំណាងលេខាធិការដ្ឋាមក្រុមការងារREDD+ ដើម្បីផ្តល់យោបល់គ្រលប់ស្តីពីផែនការងារការងារ និងវឌ្ឍនភាពនៃសកម្មភាព។ ក្រុមពិគ្រោះយោបល់ អាចជួបប្រជុំញឹកញាប់ជាងនេះ ដើម្បីពិភាក្សាយល់យោបល់គ្រលប់ដែលបានមកពីអ្នកដែលខ្លួនតំណាងឲ្យ និងដើម្បីច្របាច់យោបល់គ្រលប់បញ្ចូលគ្នា តាមការចាំបាច់។

លេខាធិការដ្ឋានមួយ នឹងត្រូវកំណត់ ដើម្បីផ្តល់ការគាំទ្រដល់ប្រតិបត្តិការរបស់ក្រុមពិគ្រោះយោបល់ ហើយលេខាធិការដ្ឋាននេះ នឹងត្រូវកំណត់ដោយសមាជិកក្រុមពិគ្រោះយោបល់ ហើយ

នឹងបានទទួលការគាំទ្រដើម្បីអាចបំពេញការងាររបស់ខ្លួន។

**៦. ការសម្រេចចិត្ត**

ក្រុមពិគ្រោះយោបល់ អាចដាក់យោបល់ និងស្នើសុំការបកស្រាយបញ្ជាក់ពីសមាជិកក្រុមការងារ។ ក្រុមពិគ្រោះយោបល់ ធ្វើការសម្រេចចិត្តដោយមតិភាគច្រើន។ ការជំទាស់ ឬអនុបវាទណាមួយ នឹងត្រូវធ្វើកំណត់ត្រាជាលាយលក្ខអក្សរ។

**៧. ការរាយការណ៍**

អ្នកតំណាងម្នាក់ៗ រាយការណ៍ជូនទៅអ្នកដែលខ្លួនតំណាងឲ្យរៀងៗខ្លួន។

**៨. រយៈពេល និងការកំណត់ពេលវេលា**

ក្រុមពិគ្រោះយោបល់រេដ+ នឹងធ្វើការងារ បីថ្ងៃ ក្នុង មួយខែ ឬច្រើនជាងនេះទៅតាមការស្នើសុំ។

**៩. មូលនិធិ**

ការគាំទ្រផ្នែកហិរញ្ញវត្ថុ នឹងត្រូវផ្តល់ជូន ប្រសិនបើអ្នកចូលរួមត្រូវបានតម្រូវឲ្យធ្វើដំណើរចេញពីកន្លែងប្រចាំការរបស់ខ្លួន ដើម្បីចូលរួមប្រជុំ។

ការគាំទ្របន្ថែមទៀត នឹងត្រូវផ្តល់ជូនសមាជិក ដែលកាន់តួនាទីជាលេខាធិការដ្ឋានសម្រាប់ក្រុមពិគ្រោះយោបល់។

ការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែម ក៏នឹងត្រូវផ្តល់ជូន សម្រាប់សកម្មភាពពិគ្រោះយោបល់ និងសកម្មភាពចូលរួមជាក់លាក់។ ការផ្តល់មូលនិធិនេះ មិនទាក់ទងដោយផ្ទាល់ជាមួយតួនាទីរបស់អ្នកតំណាងទេ។